

# ម៉ារា អ្នកត្រួសត្រាយ

ដោយ ជេសីកា ឡូសិន
( ផ្អែកទៅលើដំណើររឿងពិត )

*ខែតុលា ឆ្នាំ ២០១៨ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា*

ម៉ារាបានដាក់ទ្បេវសំពត់របស់នាង ហើយឆ្លុះកញ្ចក់ ។ គាត់មានអារម្មណ៍អស់សំណើចក្នុងការពាក់សម្លៀកបំពាក់ទៅព្រះវិហារនៅថ្ងៃសៅរ៍ ប៉ុន្តែនេះគឺជាថ្ងៃសៅរ៍មួយដ៏ពិសេស ។ វាជាសន្និសីទទូទៅ ។

« តើកូនរំភើបចិត្តចូលរួមសម័យប្រជុំស្ត្រីដែរឬទេ ? » ម៉ាក់បានសួរ ។ គាត់បានសិតសក់ឲ្យម៉ារាថ្នមៗ ។ « ម៉ាក់ចង់ឲ្យកូនព្យាយាមស្ដាប់ឲ្យបានច្រើនតាមដែលកូនអាចស្ដាប់បាន » ។

« ចាស៎ ! កូនសង្ឃឹមថា ពួកគេនឹងនិយាយអំពីរឿងរបស់ពួកអ្នកត្រួសត្រាយ ! » ម៉ារាចូលចិត្តរឿងទាំងនោះខ្លាំងបំផុត ។

ម៉ាក់បាននិយាយថា « ប្រហែលជាពួកគេនឹងនិយាយរឿងនោះ ។ តើកូនដឹងទេថា ប៉ារបស់កូនគឺជាអ្នកត្រួសត្រាយ ? »

ម៉ារាបានឆ្ងល់ ។ ប៉ារបស់នាងពុំធ្លាប់អូសរទេះទេ ។

នាងបានសួរថា « តើគាត់គឺជាអ្នកត្រួសត្រាយដោយរបៀបណា ? »

ម៉ាក់បានងក់ក្បាលបែរទៅបង្អួច សម្លឹងមើលទៅទន្លេ ។ « គាត់បាននេសាទត្រីនៅទីនោះ ពេលគាត់បានជួបពួកអ្នកផ្សព្វផ្សាយសាសនា » ។ ម៉ាក់បាននិយាយថា « គាត់គឺជាមនុស្សដំបូងគេដែលទទួលបុណ្យជ្រមុជទឹកនៅក្នុងគ្រួសាររបស់គាត់ ។ នោះហើយដែលធ្វើឲ្យគាត់គឺជាអ្នកត្រួសត្រាយនោះ ! ឥឡូវតោះទៅរកលោកយាយកូន » ។

*យាយ* កំពុងរង់ចាំពួកគេនៅមុខបន្ទប់ ។ គ្រួសាររបស់ម៉ារា និងយាយតារបស់នាងរស់នៅជាមួយគ្នា ។ យាយបានជួយមើលថែម៉ារាបន្ទាប់ពីនាងត្រឡប់មកពីរៀនវិញ ខណៈដែលប៉ាម៉ាក់របស់នាងទៅធ្វើការ ។ ឥឡូវយាយឈរនៅក្បែរម៉ូតូធំ គឺម៉ូតូធំដែលដឹកពួកគេធ្វើដំណើរជុំវិញទីក្រុង ។

ម៉ាក់បានប្រាប់ម៉ារា ពេលគាត់បើកទ្វារផ្ទះ ហើយទាញម៉ូតូចេញទៅផ្លូវថា « សាសនាចក្រទើបតែបានមកដល់ប្រទេសកម្ពុជារយៈពេល ២៥ ឆ្នាំប៉ុណ្ណោះ ។ ដូច្នេះពួកយើងទាំងអស់គ្នាគឺជាពួកអ្នកត្រួសត្រាយ ។ រួមទាំងកូនផងដែរ ! »

« តើខ្ញុំជាអ្នកត្រួសត្រាយដោយរបៀបណាទៅ ? » ម៉ារាបានឆ្ងល់ពេលនាងឡើងជិះលើម៉ូតូ ។ ម៉ាក់បានបើកម៉ូតូជាមួយយាយជិះនៅពីក្រោយ ហើយម៉ារាជិះនៅកណ្ដាល ។ ម៉ារាបានកាន់ម៉ូតូយ៉ាងណែន ពេលពួកគេធ្វើដំណើរតាមដងផ្លូវដែលមានមនុស្សច្រើន ។

ពេលពួកគេបានជិះហួសហាងកាហ្វេ ក្លិនតែបានរសាត់មកប៉ះនឹងពួកគេ ។ ប្រជាជននៅទីនេះស្ទើរតែទាំងអស់គ្នាផឹកទឹកតែ ។ ប៉ុន្តែម៉ារាមិនផឹកទេ ។ នាងបានធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ ម៉ារាបានញញឹម ។ នោះគឺជារបៀបមួយដែលនាងគឺជាអ្នកត្រួសត្រាយ !

ពេលម៉ូតូបត់ដល់កាច់ជ្រុងមួយ ម៉ារាបានឃើញ *វត្ត* មួយគឺជាវត្តព្រះពុទ្ធ ។ ជាអគារមានដំបូលក្រហមស្រួចដែលខ្ពស់ជាងអគារផ្សេងៗទៀត ។ ព្រះសង្ឃកោរសក់ គ្រងស្បង់ពណ៌លឿងគង់សិក្សានៅក្នុងទីធ្លាវត្ត ។

ម៉ារាដឹងថា ប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជាគឺជាពុទ្ធសាសនិក ។ ពួកគេពុំជឿលើព្រះយេស៊ូវគ្រីស្ទទេ ។ ប៉ុន្តែម៉ារាបានជឿ ។ ម៉ារាបានគិតថា « នោះគឺជារបៀបមួយដែលខ្ញុំគឺជាអ្នកត្រួសត្រាយ » ។ ហើយថ្ងៃនេះនាងនឹងបានស្ដាប់ព្យាការី !

ពេលម៉ូតូបត់ចូលទៅចំណតនៅព្រះវិហារ ម៉ារាបានឃើញស្ត្រីជាច្រើនបានមកដល់ ។ មានអ្នកខ្លះដើរមក ឬជិះម៉ូតូមក ។ អ្នកផ្សេងទៀតបានមកដល់ដោយជិះ *រម៉កកង់បី* ជារម៉ក់តូចមួយដែលមានម៉ូតូសណ្ដោង ។ ស្ត្រីជាច្រើនស្លៀកពាក់រ៉ូប ឬសំពត់លាតដូចម៉ារាដែរ ។ ហើយស្ត្រីខ្លះទៀតស្លៀក *សំពត់* វែងដ៏ស្រស់ស្អាតដែលធ្វើមកពីក្រណាត់មានពណ៌ចម្រុះ ។

ម៉ារា ម៉ាក់ និងយាយអង្គុយនៅក្នុងសាលាជំនុំជាមួយស្ត្រីផ្សេងទៀត ។ តាមពិតទៅ សន្និសីទបានប្រារព្ធឡើងកាលពីមួយសប្ដាហ៍មុននៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ស.រ.អា. ។ ប៉ុន្តែឥឡូវនេះប្រជាជននៅក្នុងប្រទេសកម្ពុជាអាចមើលការចាក់ផ្សាយជាភាសាខ្មែរ ។ ម៉ារានិយាយទាំងភាសាអង់គ្លេស និងភាសាខ្មែរនៅផ្ទះ ហើយនាងក៏រៀនភាសាបារាំងនៅសាលារៀនផងដែរ ។ ប៉ុន្តែប្រជាជនខ្មែរជាច្រើននាក់និយាយតែភាសាខ្មែរ ។

អ្នកនិយាយដំបូងពុំបាននិយាយរឿងអំពីពួកអ្នកត្រួសត្រាយឡើយ ។ ប៉ុន្តែក្រោយមកអ្នកនិយាយទីពីរ បានប្រាប់រឿងមួយអំពីការដើរតាមផ្លូវដែលមានដីហុយពីសាលារៀនទៅផ្ទះរបស់គាត់ ។ ផ្លូវនោះត្រូវបានហៅថា « ការសាកល្បងរបស់ក្មេងប្រុស » ហើយជួនកាលគាត់ត្រូវដោះស្បែកជើងហើយដើរដោយជើងទទេ ។ គាត់ចង់ធ្វើរឿងលំបាកៗ ដូច្នេះគាត់អាចក្លាយជាអ្នកត្រួសត្រាយ ! ម៉ារាបានញញឹម ពេលគាត់បានគិតអំពីរបៀបនានាដែល *គាត់* គឺជាអ្នកត្រួសត្រាយ ។

អ្នកនិយាយចុងក្រោយគឺជាព្យាការី ។ លោកឈរយ៉ាងខ្ពស់ ។ ម៉ារាបានស្ដាប់យ៉ាងយកចិត្តទុកដាក់ថែមទៀត ។ លោកបានមានប្រសាសន៍ថា « ខ្ញុំសូមអញ្ជើញបងប្អូនឲ្យអានព្រះគម្ពីរមរមនចាប់ពីពេលនេះរហូតដល់ចុងឆ្នាំ ។ នោះស្ថានសួគ៌នឹងបើកឡើងសម្រាប់បងប្អូន ។ ព្រះអម្ចាស់នឹងប្រទានពរដល់បងប្អូន » ។

ម៉ារាបានដឹងថា វាមិនងាយស្រួលដើម្បីអានព្រះគម្ពីរមរមនទាំងអស់ឡើយ ។ នាងបានក្រឡេកមើលស្ត្រីនៅជុំវិញនាង ។ ពួកគេទាំងអស់គ្នាបានជ្រើសរើសធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ ពួកគេទាំងអស់គ្នាបានមកយប់នេះដើម្បីស្ដាប់ព្យាការី ។ នាងនឹងធ្វើតាមព្យាការី ដូចពួកគេធ្វើតាមដែរ ។ នាងនឹងក្លាយជាអ្នកត្រួសត្រាយ ។●

*អ្នកនិពន្ធរស់នៅរដ្ឋតិចសាស ស.រ.អា. ។*

**នៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៨ ប្រធាន រ័សុល អិម ណិលសុន ក៏បានប្រកាសថា ព្រះវិហារបរិសុទ្ធមួយនឹងត្រូវសាងសង់នៅក្នុងប្រទេសកម្ពុជា !**